# យើងខ្ញុំសង្ឃឹមថាលោកអ្នកមុខជាយល់ព្រមជួយយើងខ្ញុំក្នុងការអង្កេតនេ។

## តើខ្ញុំត្រូវបានគេជ្រើសរើសតាមរបៀបណា?

យើងបានជ្រើសយកអាគាររបស់អាជ្ញាធរខាងលំនៅឋាននៅក្នុងទីក្រុងរ៉េនតុន និងសេអាតុលដែលបានបម្រើដល់គ្រួសារទាំងឡាយ។ យើងនឹងស្នើសុំឲ្យកុមារី និងស្ត្រីដែលមានអាយុចាប់ពី៦ដល់៤៩ឆ្នាំ និងកុមារា និងបុរសដែលមានអាយុចាប់ពី៦ដល់១៩ឆ្នាំ ដែលកំពុងរស់នៅក្នុងអាគារដែលទទួលបានឧបត្ថម្ភធន ឲ្យចូលរួម

## ហេតុអ្វីខ្ញុំគួរតែជួយដល់រឿងនេ?

**លោកអ្នកជួយយើងខ្ញុំឲ្យយល់ដឹងពី៖**

- របៀបកំណត់របបអាហារ ការចម្អិនអាហារក្នុងសម្ភារៈប្លាស្ទិក និងការប្រើប្រាស់ផលិតផលថែរក្សាស្បែក និងសម្ផស្ស និងផលប៉ះពាល់នៃថ្នាំសម្លាប់សត្វល្អិតកម្រិតជាតិគីមីដែលចូលទៅក្នុងរាងកាយ។
- ថាតើប្រជាជនដែលរស់នៅក្នុងអាគារដែលទទួលបានឧបត្ថម្ភធន មានសារធាតុគីមីទាំងនេះនៅក្នុងរាងកាយច្រើនឬយ៉ាងណា ដោយប្រៀបធៀបទៅនឹងប្រជាជនដែលរស់នៅរដ្ឋឬប្រទេសរបស់យើង។
- របៀបកាត់បន្ថយសារធាតុគីមីទាំងអស់នេះនៅក្នុងខ្លួនមនុស្ស។

## តើខ្ញុំនឹងទទួលបានអ្វីមួយទេប្រសិនបើខ្ញុំចូលរួម?

- មនុស្សពេញវ័យនឹងទទួលបានវីសាកាតដែលមានទឹកប្រាក់២៥ដុល្លារ
- យុវជនដែលមានអាយុចាប់ពី១២ដល់១៧ឆ្នាំ នឹងទទួលបានវីសាកាតដែលមានទឹកប្រាក់១៥ដុល្លារ
- គ្រួសារនីមួយៗនឹងទទួលបានព័ត៌មានក្នុងការជួយបន្ថយការប្រឈមនឹងថ្នាំសម្លាប់សត្វល្អិត
- ម្នាក់ៗនឹងទទួលបានដបដាក់ទឹកធ្វើពីជាតិអ៊ីណុកម្នាក់មួយ



## ប្រសិនបើលោកអ្នកចូលរួមនៅក្នុងការអង្កេតនេះ៖

មនុស្សពេញវ័យ និងជំទង់
នឹងទទួលបានបណ្ណអំណោយវីសាកាត ម្នាក់ៗនឹងទទួលបានដបទឹកធ្វើពីជាតិអ៊ីណុកម្នាក់មួយ។

## សម្រាប់ព័ត៌មានបន្ថែម៖

សូមហៅទៅកាន់លេខ៖ 1-877-494-3137
ឬចូលទៅកាន់ គេហទំព័រ៖
http://www.doh.wa.gov/biomonitoring

កូនសៀវភៅផ្សព្វផ្សាយនេះ មានជាភាសាអង់គ្លេស អេស្ប៉ាញ រុស្ស៊ី សូម៉ាលី វៀតណាម ខ្មែរ និងភាសាអាំហារិកឬទិគ្រីនយ៉ា។

សម្រាប់ជនពិការ ឯកសារទាំងនេះអាចរកបានតាមការស្នើសុំក្នុងទម្រង់ដទៃទៀត។ ដើម្បីដាក់ពាក្យស្នើសុំ សូមហៅទៅលេខ: 1-800-525-0127 (TDD/TT ហៅលេខ៧១១)

WASHINGTON Environmental Biomonitoring SURVEY



# ស្ត្រី កុមារ និងជំទង់:

## អ្នកទាំងអស់គ្នាអាចជួយយើងខ្ញុំឲ្យយល់ដឹងពីការប៉ះពាល់ទៅនឹងថ្នាំសម្លាប់សត្វល្អិត និងសារធាតុគីមីផ្សេងៗនៅក្នុងសម្ភារៈជាតិប្លាស្ទិក។

ក្រសួងសុខាភិបាលនៃរដ្ឋវ៉ាស៊ីនតោន សូមអញ្ជើញលោកអ្នកឲ្យចូលរួមនៅក្នុងការអង្កេតដ៏មានសារៈសំខាន់មួយស្តីអំពីសារធាតុគីមីដែលមាននៅតាមផ្ទះរបស់លោកអ្នក

Washington State Department of Health

DOH 210-089 March 2013 CAMBODIAN

# ការអង្កេតនឹងសាកសួរលោកអ្នកពីការប្រើប្រាស់ផលិតផលប្រភេទទាំងនេះ



គ្រឿងផាត់មុខ



កំប៉ុង ឬប្រអប់ជាតិប្លាស្ទិក



ដបទឹកជាតិប្លាស្ទិក



ម្ហូបកំប៉ុង



ថ្នាំសម្លាប់សត្វល្អិត

3/2013 CAMBODIAN

## តើនឹងមានអ្វីកើតឡើងនៅពេលក្រោយ?

ឆាប់ៗនេះ បុគ្គលិកចុះមូលដ្ឋានដែលធ្វើការនៅក្រសួងសុខាភិបាលរដ្ឋវ៉ាស៊ីនតោននឹងចុះទៅកាន់គេហដ្ឋានរបស់លោកអ្នក ដើម្បីពន្យល់អំពីការអង្កេត និងសាកសួរថាតើលោកអ្នកចង់ចូលរួមដែរឬទេ ពួកគេនឹងមានរូបថត និងអត្តសញ្ញាណបណ្ណ ហើយពាក់អាវធំដែលសរសេថា ក្រសួងសុខាភិបាលរដ្ឋវ៉ាស៊ីនតោន ប្រសិនបើលោកអ្នកចង់ចូលរួម ការចុះទៅនេះ នឹងចំណាយពេលរហូតដល់៤៥នាទី ដោយអាស្រ័យលើ ចំនួនមនុស្សនៅក្នុងផ្ទះរបស់លោកអ្នកចង់ចូលរួម បុគ្គលិកចុះទៅ នឹងផ្តល់ ឬទូរស័ព្ទហៅអ្នកបកប្រែ ប្រសិនបើចាំបាច់

## តើគេនឹងសុំឲ្យខ្ញុំធ្វើអ្វីខ្លះបើខ្ញុំចូលរួម?

- ចូរផ្តល់ឲ្យយើងនូវសំណាកទឹកនោមចំនួនពីរ សម្រាប់តេស្តរកមើលជាតិថ្នាំសម្លាប់សត្វល្អិត និងសារធាតិគីមីនៅក្នុងប្លាស្ទិក។
- ចូរបង្កកទឹកនោមរហូតដល់ពេលយើងខ្ញុំមកយកវា។
- ចូរឆ្លើយសំណួរនានារបស់លោកអ្នកអំពីលោកអ្នក ផ្ទះរបស់លោកអ្នក ដូចជា អាហារដែលលោកអ្នកទទួលទាន ផលិតផលប្លាស្ទិកដែលលោកអ្នកប្រើប្រាស់ និងការប្រើប្រាស់ថ្នាំបាញ់សម្លាប់សត្វល្អិត
- ការងារទាំងអស់នេះនឹងចំណាយពេលប្រហែល៣០នាទី

## តើនរណាខ្លះនឹងដឹងអំពីលទ្ធផលរបស់ខ្ញុំ?

មានតែក្រុមអង្កេតរបស់ក្រសួងសុខាភិបាលរដ្ឋវ៉ាស៊ីនតោនទេដែលដឹងថានរណាចូលរួមក្នុងការអង្កេតនេះ។ យើងនឹងរក្សាព័ត៌មានទាំងអស់ជាការសម្ងាត់ មិនឲ្យលេចឮឈ្មោះនៅលើព័ត៌មានណាមួយដែលយើងប្រមូលនោះទេ យើងនឹងផ្តល់របាយការណ៍តែទៅលើលទ្ធផលរបស់ក្រុមអង្កេតទាំងមូល

## តើសារធាតុគីមីអ្វីខ្លះដែលលោកអ្នកចង់ដឹង?

### ថ្នាំសម្លាប់សត្វល្អិត សារធាតុប៊ីភីអេ និង សារធាតុផ្លាលិកអាស៊ីត

- **ថ្នាំសម្លាប់សត្វល្អិត**ត្រូវគេប្រើប្រាស់នៅក្នុង និងជុំវិញអាគារស្នាក់នៅ និងក្នុងកសិដ្ឋាន។
- **ប៊ីសហ្វេណុល អា** (BPA) ត្រូវគេប្រើនៅក្នុងគ្រឿងប្លាស្ទិករឹង ដូចជាដបទឹកដោះគោ និងដបទឹកចាស់ៗ និងនៅក្នុងសារធាតុស្រោបផ្ទៃខាងក្នុងកំប៉ុងអាហារ។
- **សារធាតុផ្លាលិកអាស៊ីត** ត្រូវគេប្រើនៅក្នុងគ្រឿងប្លាស្ទិកទន់ ផលិតផលវីនីល និងសម្ភារៈវេចខ្ចប់អាហារ។ សារធាតិទាំងនេះត្រូវគេរកឃើញផងដែរនៅក្នុងផលិតផលថែរក្សាស្បែក និងសម្អស្ស ដូចជាសាប៊ូកក់សក់ជាដើម។ឡេ និងគ្រឿងផាត់មុខ។

## ហេតុអ្វីបានជាក្រសួងសុខាភិបាលចង់ដឹងពីសារធាតុគីមីទាំងនេ?

- ក្រសួងសុខាភិបាលធ្វើការងារដើម្បីគាំពារសុខភាព តាមរយៈការបង្ការ និងការអប់រំ។
- ការសិក្សាស្រាវជ្រាវបង្ហាញឲ្យឃើញថាសារធាតិគីមីទាំងនេះ អាចបង្កគ្រោះថ្នាក់ចំពោះសត្វ និង ជីវិតដំបូង។ ក្រុមអ្នកវិទ្យាសាស្ត្រចង់ដឹងថែមទៀតអំពីថាតើសារធាតុគីមីទាំងនេះមានប៉ុណ្ណានៅក្នុងខ្លួន កុមារ ក្មេងជំទង់ និងស្រ្តីដែលមានអាយុចាប់ពី២០ដល់៤៤ឆ្នាំ។

## តើនឹងមានអ្វីកើតឡើងបើខ្ញុំមិនចូលរួម?

ការចូលរួមក្នុងការសិក្សានេះគឺជាជម្រើសរបស់លោកអ្នកការចូលរួមចាជម្រើសរបស់លោកអ្នក។ លោកអ្នកអាចដកខ្លួនពេលណាក៏បានដែរ។ លោកអ្នកអាចទូរសព្ទហៅទៅកាន់ក្រសួងសុខាភិបាលរដ្ឋវ៉ាស៊ីនតោនតាមរយៈទូរសព្ទឥតគិតថ្លៃ លេខ: 1-877-494-3137 សម្រាប់ជាព័ត៌មាន ឬមិនមាននរណាម្នាក់នៅក្នុងគ្រួសាររបស់លោកអ្នកចូលរួម។ លោកអ្នកក៏អាចទូរសព្ទហៅផងដែរប្រសិនបើលោកអ្នកមិនរស់នៅក្នុងអាគារឧបត្ថម្ភធន ឬមិនមានក្មេងស្រីឬស្រ្តីដែលមានអាយុចាប់ពី៦ដល់៤៤ឆ្នាំ ឬមិនមានកុមារា និងបុរសចាប់ពីអាយុ៦ដល់១៩ឆ្នាំ។ ប្រសិនបើពេលក្រោយលោកអ្នកចង់ចូលរួមសូមទូរស័ព្ទមកកាន់ពួកយើង។